ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផែនការសកម្មភាព
អភិរក្សដំរីអាស៊ីនៅកម្ពុជា ២០២០-២០២៩

រាជធានីភ្នំពេញ ឆ្នាំ២០២០

អ.ក.ធ(២០២០) ផែនការសកម្មភាពអភិរក្សជំរីអាស៊ីនៅកម្ពុជា ២០២០-២០២៩

ផលិតដោយ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ (អ.ក.ធ)នៃក្រសួងបរិស្ថាន ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ(FFI)

អាសយដ្ឋាន៖ ជាន់ទី២ នៃក្រសួងបរិស្ថាន អគារមរតកតេជោ ដីទ្បូលេខ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

មាតិកា

ពាក្យបំព្រួញ និងអក្សរកាត់ iii

អារម្ភកថា iv

សេចក្តីផ្លែងអំណរគុណ vi

សេចក្តីសង្ខេប ១

ផែនការសកម្មភាពអភិរក្សដំរីអាស៊ីនៅកម្ពុជា ២០២០-២០២៩ ..... ៣

១. សាវតារ ៣

១.១ ស្ថានភាពដំរីអាស៊ីនៅកម្ពុជា ៣

១.២ បញ្ហាអាទិភាព ៧

១.២.១ ការបាត់បង់ និងការបែកខ្ញែកទីជម្រក ៧

១.២.២ ជម្លោះរវាងមនុស្ស និងដំរីព្រៃ ៩

១.២.៣ ការបរបាញ់ ១១

១.២.៤ ការចាប់ដំរីព្រៃមកចិញ្ចឹម ១២

១.២.៥ ហ្វូងដំរីព្រៃមានចំនួនតិច ១៣

១.២.៦ ការរំខានដោយមនុស្ស ១៣

២. យុទ្ធសាស្ត្រ និងការវិភាគយុទ្ធសាស្ត្រ ១៥

៣. ផែនការសកម្មភាពយុទ្ធសាស្ត្រ ១៧

៣.១ ផែនការសកម្មភាពយុទ្ធសាស្ត្រទី១៖ កាត់បន្ថយការ
បាត់បង់ទីជម្រក ១៧

៣.២ ផែនការសកម្មភាពយុទ្ធសាស្ត្រទី២៖ អភិរក្ស និងតភ្ជាប់

ច្រករបៀង និងហ្វូងដំរីព្រៃឡើងវិញ ១៧
៣.៣ ផែនការសកម្មភាពយុទ្ធសាស្ត្រទី៣៖ ពង្រឹងការអនុវត្តច្បាប់ ១៨
៣.៤ ផែនការសកម្មភាពយុទ្ធសាស្ត្រទី៤៖ បង្ការមិនឱ្យមានការ
ចាប់ដំរីព្រៃមកចិញ្ចឹម ១៩
៣.៥ ផែនការសកម្មភាពយុទ្ធសាស្ត្រទី៥៖ បន្ធូរបន្ថយជម្លោះរវាង
មនុស្ស និងដំរីព្រៃ ១៩
៣.៦ ផែនការសកម្មភាពយុទ្ធសាស្ត្រទី៦៖ អប់រំផ្សព្វផ្សាយ ២០
៣.៧ ផែនការសកម្មភាពយុទ្ធសាស្ត្រទី៧៖ សិក្សាស្រាវជ្រាវ
និងតាមដានត្រួតពិនិត្យចំនួនដំរីព្រៃ ២១
៤. ធនធានហិរញ្ញវត្ថុ ២៧
៥. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ២៨
៦. សេចក្តីសន្និដ្ឋាន ២៨
ឯកសារយោង ៣១

ពាក្យបំព្រួញ និងអក្សរកាត់

CBD	Convention on Biological Diversity	អនុសញ្ញាជីវៈចម្រុះ
CECG	Cambodian Elephant Conservation Group	ក្រុមអភិរក្សដំរីព្រៃកម្ពុជា
CI	Conservation International	អង្គការអភិរក្សអន្តរជាតិ
CITES	Convention on International Trade in Endangered Species of Wild Fauna and Flora	អនុសញ្ញាពាណិជ្ជកម្មអន្តរជាតិ លើប្រភេទសត្វព្រៃ និងរុក្ខជាតិ ដែលជិតផុតពូជ
FFI	Fauna & Flora International	អង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ
IUCN	International Union for Conservation of Nature	អង្គការសហភាពអន្តរជាតិដើម្បី ការអភិរក្សធម្មជាតិ
MIKE	Monitoring of Illegal Killing of Elephant	កម្មវិធីតាមដានស្តីពីការសម្លាប់ដំរី ព្រៃដោយខុសច្បាប់
MJP	Maddox Julie-Pitt Foundation	មូលនិធិម៉ាដក្សចូលីកីត
WA	Wildlife Alliance	អង្គការសម្ព័ន្ធមិត្តសត្វព្រៃ
WCS	Wildlife Conservation Society	អង្គការសមាគមអភិរក្សសត្វព្រៃ
WWF	World Wildlife Fund for Nature	អង្គការមូលនិធិសកលសម្រាប់ អភិរក្សធនធានធម្មជាតិ

អារម្ភកថា

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព និងស្ថិរភាពនយោបាយរឹងមាំ ក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិជាច្រើន ដើម្បីធានាឱ្យបាននូវតុល្យភាពទាំងការអភិវឌ្ឍ និងការអភិរក្ស លើនិរន្តភាពបរិស្ថាន និងធនធានធម្មជាតិ។

ក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនផ្ទៃដីតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះដែលបង្កើតបានជាប្រព័ន្ធតំបន់ការពារធម្មជាតិគ្របដណ្តប់លើផ្ទៃដីប្រមាណ ៧,២លានហិកតា ស្មើនឹងប្រមាណជាង ៤០% នៃផ្ទៃដីប្រទេស។ ដើម្បីគ្រប់គ្រងតំបន់ការពារធម្មជាតិទាំងអស់នេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ក្រសួងបរិស្ថានបាននឹងកំពុងសហការជាមួយនឹងក្រសួង ស្ថាប័ន ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់រួមមាន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដើម្បីគាំពារបរិស្ថាន ការអភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិ និងជីវៈចម្រុះប្រកបដោយចីរភាព។

ជាផ្នែកមួយនៃការងារអភិរក្ស ក្រសួងបរិស្ថានបានផ្តោតការយកចិត្តទុកដាក់លើការអភិរក្សសត្វដំរីអាស៊ីនៅកម្ពុជា ដែលជាប្រភេទសត្វព្រៃដ៏មានសារៈសំខាន់ទាំងផ្នែកវប្បធម៌ និងផ្នែកមុខងារប្រព័ន្ធអេកូឡូស៊ី ហើយក្រសួងក៏បានយកចិត្តទុកដាក់លើសក្តានុពល ក្នុងការការពារ និងអភិរក្សប្រភេទសត្វផ្សេងៗទៀតផងដែរ ក្នុងកម្រិតវិសាលភាពដែនជម្រករបស់ពួកវា។ ហើយបច្ចុប្បន្ននេះ សត្វដំរីត្រូវបានប៉ាន់ស្មានថា មានរស់នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជាមានចំនួនពី ៤០០ ទៅ ៦០០ក្បាលប៉ុណ្ណោះ។ ដោយសារតែការថយចុះនៃទីជម្រកទូទាំងប្រទេសមិនស្ថិតនៅជាប់គ្នា ជាហេតុធ្វើឱ្យដំរីទាំងនោះកំពុងរស់នៅបែកខ្ញែកពីគ្នា និងមានផលប៉ះពាល់ដល់លទ្ធភាពនៃការធ្វើអន្តរកម្ម ការបន្តពូជ និងក្នុងការអភិរក្សរយៈពេលវែង។ កត្តាព្រួយបារម្ភទាំងនេះ បានជំរុញឱ្យមានការរៀបចំនូវផែនការសកម្មភាពអភិរក្សដំរី

អាស៊ីរយៈពេល១០ឆ្នាំ (២០២០-២០២៩) ក្នុងគោលបំណងធ្វើជាត្រីវិស័យបង្ហាញផ្លូវ សម្រាប់លើកកម្ពស់ការគ្រប់គ្រងប្រភេទសត្វព្រៃ ជាពិសេសជំរីព្រៃអាស៊ីនៅកម្ពុជាឱ្យ ស្ថិតស្ថេរ គង់វង្ស និងបង្កើនចំនួនឡើងវិញ សម្រាប់ជាកេរមរតក វប្បធម៌ធម្មជាតិ និងជាឧត្តមប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់។ យើងខ្ញុំសង្ឃឹមថា ផែនការសកម្មភាពនេះ នឹងផ្តល់ឱកាសឱ្យយើងទាំងអស់គ្នា អាចចូលរួមជាមួយសហគមន៍ជាតិ និងអន្តរ ជាតិ ក្នុងការបង្កើនជំនាញបច្ចេកទេស និងបណ្តាញការងារជាច្រើន សំដៅធានាដល់ កិច្ចការពារ និងអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះគ្រប់ប្រភេទ ពិសេសប្រភេទសត្វកម្រនានាដូចជាជំរីអាស៊ីដែលកំពុងមានវត្តមាននៅក្នុងប្រព័ន្ធតំបន់ ការពារធម្មជាតិកម្ពុជាយើងនេះ។

ក្នុងនាមក្រសួងបរិស្ថាន ខ្ញុំសូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រ កម្ពុជា** ដែលតែងតែយកចិត្តទុកដាក់លើវិស័យបរិស្ថាន និងធនធានធម្មជាតិ ហើយ ក៏សូមថ្លែងអំណរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រី នៃក្រសួងបរិស្ថាន ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ វិស័យឯកជន និងប្រជា សហគមន៍មូលដ្ឋានដែលបានចូលរួម គាំទ្រ និងផ្តល់កិច្ចសហការយ៉ាងល្អក្នុងការ រៀបចំឯកសារដ៏មានតម្លៃនេះឱ្យកើតចេញជារូបរាងឡើង។

ថ្ងៃ សៅរ៍ ១០ ភាច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២០

រដ្ឋមន្ត្រី

សាយ សំអាល់

សេចក្តីថ្លែងអំណរគុណ

ជាបឋម សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលជានិច្ចកាលបានណែនាំ លើកទឹកចិត្ត និងផ្តល់ការគាំទ្រយ៉ាងកក់ក្តៅក្នុងការបង្កើតផែនការសកម្មភាពអភិរក្សជំរីអាស៊ីនៅកម្ពុជារយៈពេល១០ឆ្នាំ (២០២០-២០២៩)នេះឡើង ដើម្បីរួមចំណែកដល់ការការពារ អភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពនៅកម្ពុជា។ សូមថ្លែងអំណរគុណដល់ឯកឧត្តម **ម៉ាស សុផល** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងឯកឧត្តម **គឹម ណុាង** ដែលបានជួយជំរុញ ផ្តល់ការគាំទ្រ និងទស្សនទាន តាំងពីការប្រមូលទិន្នន័យ ការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់ជាច្រើនសម្រាប់រៀបចំឯកសារនេះឡើង។ សូមថ្លែងអំណរគុណដល់មន្ត្រីនៃនាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប ដែលបានជួយត្រួតពិនិត្យ កែតម្រូវពាក្យពេចន៍ និងខ្លឹមសារប្រកបដោយអត្ថន័យស្ថាបនាដើម្បីឱ្យឯកសារនេះអាចបោះពុម្ពបានដោយជោគជ័យ។

សូមថ្លែងអំណរគុណដល់អង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ(FFI) ជាពិសេស «ក្រុមអភិរក្សជំរីព្រៃនៅកម្ពុជា(CECG)» ដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំឯកសារនេះតាំងពីដើមរហូតដល់ចប់ ដោយបានផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកា សម្រាប់ការរៀបចំផែនការសកម្មភាពអភិរក្សជំរីអាស៊ីរយៈពេល១០ឆ្នាំនេះ ឱ្យចេញជារូបរាងឡើង។

សូមថ្លែងអំណរគុណដល់មន្ត្រីជំនាញ និងនាយកតំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថាន មន្ត្រីរដ្ឋបាលព្រៃឈើ អង្គការអភិរក្សនានា(CI MJP WA WCS WWF) ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ដែលបានផ្តល់ព័ត៌មានតាមរយៈការចូលរួមប្រជុំនៅតាម

បណ្តាខេត្តនានា និងសិក្ខាសាលាជាតិ។

សូមថ្លែងអំណរគុណដល់អង្គការ FFI WWF WA និង WCS ដែលបានចូលរួមកែសម្រួល និងផ្តល់យោបល់ស្តាបនាលើសេចក្តីព្រាងឯកសារផែនការសកម្មភាពសម្រាប់អភិរក្សដំរីអាស៊ីរយៈពេល១០ឆ្នាំនេះ។ ជាចុងបញ្ចប់ សូមថ្លែងអំណរគុណចំពោះអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន អង្គការ FFI និងអង្គការ WWF ដែលបានផ្តល់រូបភាពដំរីព្រៃសម្រាប់ផែនការសកម្មភាពនេះ។

សេចក្តីសង្ខេប

ប្រទេសកម្ពុជាមានប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ប្រមាណ៤០%នៃផ្ទៃដីប្រទេស ដែលស្ថិតនៅក្រោមយុត្តាធិការក្រសួងបរិស្ថាន។ យោងតាមតម្រូវការ និងភាពចាំបាច់នៃផែនការសកម្មភាពសម្រាប់ការអភិរក្សសត្វបង្គោលនៅកម្ពុជា អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន បានសហការជាមួយអង្គការដៃគូ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតដើម្បីរៀបចំផែនការសកម្មភាពអភិរក្សដំរីអាស៊ីនេះឡើង ក្រោមការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ(FFI)។ ផែនការសកម្មភាពអភិរក្សដំរីអាស៊ីរយៈពេល១០ឆ្នាំនេះមានគោលបំណងបង្កើតផែនការមួយដែលអាចកំណត់កត្តាគំរាមកំហែងសម្រាប់ការអភិរក្សដំរីព្រៃ និងកំណត់វិធានការចាំបាច់នានាដែលអាចទប់ស្កាត់ការបាត់បង់សត្វប្រភេទនេះ ដើម្បីធានាឱ្យបាននូវការអភិរក្សដំរីអាស៊ីរយៈពេលវែងនៅទូទាំងប្រទេសកម្ពុជា។ ដំណើរការសំខាន់ៗនៃការរៀបចំផែនការសកម្មភាពសម្រាប់អភិរក្សដំរីអាស៊ី១០ឆ្នាំនេះបានចាប់ផ្តើមតាំងពីការធ្វើសិក្ខាសាលាថ្នាក់ជាតិនាឆ្នាំ២០១២មកម្ល៉េះ ហើយក៏មានការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយមន្ត្រីជំនាញពាក់ព័ន្ធ មន្ត្រីថ្នាក់ខេត្ត អង្គការជាតិ អង្គការអន្តរជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍន៍នានា និងប្រជាសហគមន៍មូលដ្ឋាន។

ផែនការសកម្មភាពអភិរក្សដំរីអាស៊ី១០ឆ្នាំនេះ បានដាក់ចេញនូវសកម្មភាពយុទ្ធសាស្ត្រចំនួនប្រាំពីរ រួមមាន សកម្មភាពយុទ្ធសាស្ត្រទី១ កាត់បន្ថយការបាត់បង់ទីជម្រក សកម្មភាពយុទ្ធសាស្ត្រទី២ អភិរក្ស និងតភ្ជាប់ច្រករបៀង និងហ្វូងដំរីព្រៃឡើងវិញ សកម្មភាពយុទ្ធសាស្ត្រទី៣ ពង្រឹងការអនុវត្តច្បាប់ សកម្មភាពយុទ្ធសាស្ត្រទី៤ បង្ការមិនឱ្យមានការចាប់ដំរីព្រៃមកចិញ្ចឹម សកម្មភាពយុទ្ធសាស្ត្រទី៥ បន្ថយ

បន្ថយជម្លោះរវាងមនុស្ស និងដំរីព្រៃ សកម្មភាពយុទ្ធសាស្ត្រទី៦ អប់រំផ្សព្វផ្សាយ សកម្មភាពយុទ្ធសាស្ត្រទី៧ សិក្សាស្រាវជ្រាវ និងតាមដានត្រួតពិនិត្យចំនួនដំរីព្រៃ។ ដើម្បីសម្រេចឱ្យបាននូវសកម្មភាពយុទ្ធសាស្ត្រទាំងប្រាំពីរនេះ ត្រូវតែអនុវត្តនូវសកម្មភាពអាទិភាពចំនួន៣១។

សកម្មភាពទាំងអស់នឹងត្រូវយកទៅអនុវត្តនៅទូទាំងប្រទេស ដើម្បីធានាថាប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សដីរ:ចម្រុះទាំងនេះឆ្លើយតបទៅនឹងគោលបំណងនៃការបង្កើត ដែលចាំបាច់ត្រូវវាយតម្លៃជាប្រចាំពីស្ថានភាព និន្នាការ មុខងារ តួនាទី តម្លៃការគំរាមកំហែង និងផលប៉ះពាល់ ហើយស្វែងរកវិធានការដើម្បីដោះស្រាយការគំរាមកំហែង និងកាត់បន្ថយសម្ពាធទាំងនេះ។ ព័ត៌មានដែលបានមកពីការវាយតម្លៃនេះជាផែនទីបង្ហាញផ្លូវសម្រាប់ជ្រើសរើសសកម្មភាព និងពេលវេលាសមស្របបំផុតសម្រាប់បញ្ចូលទៅក្នុងផែនការសកម្មភាព ព្រមទាំងកំណត់ពីតម្រូវការចាំបាច់សម្រាប់បង្កើនសមត្ថភាពធនធានមនុស្ស ស្ថាប័ន បច្ចេកវិទ្យា និងហិរញ្ញវត្ថុ។

ផែនការសកម្មភាពអភិរក្សជំរីអាស៊ីនៅកម្ពុជា ២០២០-២០២៩

១. សាវតារ

នៅក្នុងប្រព័ន្ធចំណាត់ថ្នាក់ភាវៈមានជីវិត ជំរីអាស៊ីត្រូវបានចាត់ចូលក្នុងរជ្ជៈសត្វ សាខាការដេ(Chordata) ថ្នាក់ថនិកសត្វ លំដាប់ប្រូបូស៊ីដេ(Proboscidea) អម្បូរជំរី (Elephantidae) ដែលមានឈ្មោះវិទ្យាសាស្ត្រថា *Elephas maximus*។ អង្គការ សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ(IUCN) បានចុះបញ្ជីជំរីអាស៊ីជាប្រភេទ ដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ(EN)។ នៅក្នុងអនុសញ្ញាពាណិជ្ជកម្មអន្តរជាតិ លើប្រភេទសត្វព្រៃ និងរុក្ខជាតិ ឬអនុសញ្ញាសាយតេស(CITES) ជំរីអាស៊ីត្រូវបាន ចាត់បញ្ចូលក្នុងឧបសម្ព័ន្ធI។ ប្រទេសកម្ពុជាជាប្រទេសហត្ថលេខីនៃអនុសញ្ញាសាយតេស និងអនុសញ្ញាជីវៈចម្រុះ(CBD) ដែលកម្ពុជាបានបង្ហាញពីការតាំងចិត្តក្នុងការអភិរក្ស ប្រភេទដែលកំពុងទទួលរងគ្រោះ និងជិតផុតពូជទាំងនោះ។

១.១ ស្ថានភាពជំរីអាស៊ីនៅកម្ពុជា

ក្នុងរយៈពេល ៦០ ទៅ ៧០ឆ្នាំចុងក្រោយនេះ ចំនួនជំរីអាស៊ីនៅលើពិភពលោក បានថយចុះប្រហែលជា៥០%(Choudry *et al.* 2008) ចំណែកឯទីជម្រករបស់វា បានបាត់បង់អស់ជិត៩០%(Hedge *et al.* 2008)។ ក្នុងចំណោមជំរីអាស៊ីសរុប ប្រមាណពី ៣៩ ៤៦៣ក្បាល ទៅ ៤៧ ៤២៧ក្បាល ដែលកំពុងរស់នៅក្នុងព្រៃសព្វថ្ងៃ ប្រហែលជា ៧៥% រស់នៅក្នុងប្រទេសឥណ្ឌា និងស្រីលង្កា(Fernando & Pastorini 2011)។ ជំរីអាស៊ីត្រូវបានចាត់ទុកថាជាប្រភេទសត្វបង្គោល(Keystone species) ដ៏សំខាន់ដោយសារសារៈសំខាន់ខាងផ្នែកវប្បធម៌ តួនាទីនៅក្នុងប្រព័ន្ធអេកូឡូស៊ី និង

សក្តានុពលដែលអាចការពារប្រភេទផ្សេងៗទៀតក្នុងដែនដីរបស់វា។ ដំរីអាស៊ីជាប្រភេទតិណាសីដែលស៊ីរុក្ខជាតិ និងផ្លែឈើជាអាហារ ហើយពួកវាភាគច្រើនរស់នៅក្នុងព្រៃគ្រប់ប្រភេទ រួមទាំងវាលស្មៅ និងព្រៃគុម្ពោត។

ចំនួនដំរីព្រៃនៅក្នុងប្រទេសកម្ពុជាបានថយចុះយ៉ាងខ្លាំង ហើយបច្ចុប្បន្ន គេបានប៉ាន់ស្មានថាមានចំនួនពី ៤០០ ទៅ ៦០០ ក្បាលតែប៉ុណ្ណោះ (Maltby & Bourchier 2011; Gray *et al.* 2014)។ ដំរីព្រៃដែលនៅសេសសល់តិចនេះក៏កំពុងរស់នៅជាក្រុមតូចៗក្នុងទីជម្រកដាច់ដោយឡែកពីគ្នា។ ការប៉ាន់ស្មាននូវចំនួនដំរីព្រៃជាអប្បបរមាចាំបាច់សម្រាប់ការអភិរក្សរយៈពេលវែង តម្រូវឱ្យមានដំរីព្រៃពេញវ័យដែលអាចបន្តពូជបានចំនួន ៥០០ក្បាល ដែលក្នុងនោះគួរមានឈ្មោលចំនួន០១ក្នុងចំណោមដំរីញី០៥ក្បាល និងដង់ស៊ីតេដំរីព្រៃចំនួន ០,៥ក្បាល ក្នុង ១គីឡូម៉ែត្រការ៉ែ។ ចំណែកឯការប៉ាន់ស្មានពីទំហំផ្ទៃដីទីជម្រកជាប់ៗគ្នាអប្បបរមាចាំបាច់សម្រាប់ការអភិរក្សដំរីព្រៃរយៈពេលវែង តម្រូវឱ្យមានផ្ទៃដីព្រៃជាប់ៗគ្នាទំហំ ៤ ៤០០គីឡូម៉ែត្រការ៉ែ(Sukumar 1992)។ បើយោងតាមតម្រូវការនៃទំហំទីជម្រក និងចំនួនដំរីព្រៃអប្បបរមា ស្ថានភាពដំរីព្រៃនៅកម្ពុជាកំពុងស្ថិតក្នុងភាពប្រកាសអាសន្នហើយ។ ក្រុមនីមួយៗក្នុងចំណោមដំរីព្រៃទាំង២ក្រុមសំខាន់ៗសព្វថ្ងៃ(ក្រុមនៅតំបន់ភ្នំក្រវាញ និងក្រុមនៅតំបន់ខ្ពង់រាបភាគខាងកើត)មានចំនួនតិចជាងចំនួនអប្បបរមា៥០០ក្បាល។ ផ្ទៃដីទីជម្រកនៅតំបន់ជួរភ្នំក្រវាញ តំបន់ខ្ពង់រាបភាគខាងកើត និងតំបន់រ៉ៃ:ជ័យ-ខេត្តណាំហ្គុង(ឡាវ)នៅអាចបំពេញតាមតម្រូវការអប្បបរមា ៤ ៤០០គីឡូម៉ែត្រការ៉ែនៅឡើយ។ ដូច្នេះហើយ យើងគួរមានវិធានការអភិរក្សជាបន្ទាន់ និងចាំបាច់បំផុតមួយដើម្បីបង្ការកុំឱ្យដំរីអាស៊ីផុតពូជពីក្នុងប្រទេសកម្ពុជា។

នៅតំបន់ជួរភ្នំក្រវាញ គេបានប៉ាន់ស្មានថា តំបន់ដែលមានដំរីព្រៃច្រើនជាងគេ

គឺឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង។ ចំណែកនៅក្នុងដែនជម្រកសត្វព្រៃតាតៃ ឧទ្យានជាតិបុទុមសាគរ ឧទ្យានជាតិព្រះសុវាម្រិត-កុសុម:(គិរីរម្យ) ដែនជម្រកសត្វព្រៃភ្នំសំកុស និងតំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត គេបានប៉ាន់ស្មានថាមានហ្វូងដំរីរស់នៅបែកខ្ញែកពីគ្នា ដែលហ្វូងនីមួយៗអាចមានចំនួនតិចជាង២០ក្បាល។ យោងតាមការបោះពុម្ពផ្សាយរបស់លោក Maltby និងលោក Bourchier នៅឆ្នាំ២០១១ ដំរីព្រៃនៅក្នុងតំបន់ជួរភ្នំក្រវាញត្រូវបានប៉ាន់ស្មានថាមានចំនួនសរុបប្រហែលជា១៧៥ក្បាល។ លោក Hedges និងអ្នកដទៃទៀតនៅឆ្នាំ២០០៨បានប៉ាន់ស្មានថា ផ្ទៃដីទីជម្រកសំខាន់ៗរបស់ដំរីព្រៃក្នុងតំបន់ជួរភ្នំក្រវាញអាចមានទំហំ ៦ ៤២៩គីឡូម៉ែត្រការ៉េ។ យ៉ាងណាមិញ តម្រូវការផ្នែកអភិវឌ្ឍន៍ផ្សេងៗ និងការតាំងទីលំនៅថ្មីក្នុងអំឡុងរយៈពេល១០ឆ្នាំចុងក្រោយ បានធ្វើឱ្យទំហំផ្ទៃដីទីជម្រកសមស្របខាងលើនេះ រួមទាំងគុណភាពទីជម្រក និងភាពតភ្ជាប់នៃទីជម្រកមានការថយចុះ។

តំបន់ទេសភាពខ្ពង់រាបភាគខាងកើតក្នុងខេត្តមណ្ឌលគិរី រួមមាន ដែនជម្រកសត្វព្រៃភ្នំព្រេច ដែនជម្រកសត្វព្រៃស្រែពក និងដែនជម្រកសត្វព្រៃកែវសីមា។ តាមការសិក្សាប៉ាន់ស្មានបានបង្ហាញថា មានដំរីព្រៃចំនួនពី ១០១ ទៅ ១៣៩ក្បាល មានវត្តមាននៅក្នុងដែនជម្រកសត្វព្រៃកែវសីមា(Pollard *et al.* 2008) ដំរីពី១០១ ទៅ ១៧៥ក្បាលមាននៅក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច និងយ៉ាងហោចណាស់ក៏មានដំរីព្រៃចំនួន ២១ក្បាលដែរដែលមានវត្តមាននៅក្នុងដែនជម្រកសត្វព្រៃស្រែពក(Gray *et al.* 2014)។ បើយោងតាមលទ្ធផលកិច្ចពិភាក្សាថ្នាក់ខេត្ត ហ្វូងដំរីព្រៃមួយចំនួនផ្លាស់ទីរវាងដែនជម្រកសត្វព្រៃស្រែពក និងឧទ្យានជាតិយុគដុងនៃប្រទេសវៀតណាម។ ទីជម្រកសំខាន់ៗសម្រាប់ដំរីព្រៃនៅក្នុងតំបន់ទេសភាពខ្ពង់រាបភាគខាងកើតត្រូវបានប៉ាន់ប្រមាណថាមានផ្ទៃដីសរុបប្រហែលជា ២ ១៥៤គីឡូម៉ែត្រការ៉េប៉ុណ្ណោះ ដែលក្នុងនោះ ទីជម្រកចំនួន ១ ១២៦គីឡូម៉ែត្រការ៉េ ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច

៤០៨គីឡូម៉ែត្រការ៉េ ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃស្រែពក និង ៦២០គីឡូម៉ែត្រការ៉េ ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា (Hedges 2008)។ ព័ត៌មានអំពីរបាយ និងចលនាផ្លាស់ទីតាមរដូវកាលនៅមានភាពខ្វះចន្លោះ និងតម្រូវឱ្យមានការសិក្សាស្រាវជ្រាវបន្ថែមទៀត ជាពិសេសដើម្បីដឹងថា តើដំរីនៅក្នុងតំបន់ទេសភាពខ្ពង់រាបភាគខាងកើតអាចនៅមានលទ្ធភាពផ្លាស់ទីទៅមកពីតំបន់មួយទៅតំបន់មួយ បង្កើតបានជាក្រុមធំមួយ (meta-population) ឬក៏ហ្វូងដំរីនានាក្នុងតំបន់ខ្ពង់រាបនេះត្រូវបានកាត់ផ្តាច់ពីគ្នាទៅហើយ។ ជារួម ចំនួនដំរីព្រៃសរុបទាំងអស់នៅតំបន់ខ្ពង់រាបភាគខាងកើតអាចមានរហូតដល់ទៅ ៣០០ក្បាល (Gray *et al.* 2014)។

ក្រៅពីនេះ មានក្រុមដំរីតូចៗមួយចំនួនដែលកំពុងរស់នៅដាច់ប៉ែកពីគេ ដូចជា ដំរី៥ក្បាលនៅក្នុងដែនជម្រកសត្វព្រៃឆែប និងយ៉ាងហោចណាស់១៣ក្បាលនៅក្នុងដែនជម្រកសត្វព្រៃ«ព្រៃឡង់» (Hayes *et al.* 2015)។ ការអង្កេតបឋមតាមម៉ាស៊ីនថតស្វ័យប្រវត្តបង្ហាញអំពីវត្តមានដំរីនៅក្នុងឧទ្យានជាតិរ៉ៃជ័យ ប៉ុន្តែពុំទាន់មានការសិក្សាស្រាវជ្រាវពេញលេញណាមួយធ្វើការប៉ាន់ស្មានចំនួនដំរីក្នុងឧទ្យានជាតិនេះនៅឡើយទេ។ ម្យ៉ាងវិញទៀត ដំរីនៅក្នុងឧទ្យានជាតិរ៉ៃជ័យក៏ទំនងជាធ្វើការផ្លាស់ទីទៅមកទៅកាន់ខេត្តអ័ត្ត:ពើប្រទេសឡាវផងដែរ។

ដំរីព្រៃនៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ដែនជម្រកសត្វព្រៃលំផាត់ និងដែនជម្រកសត្វព្រៃភ្នំណាំលៀ បានបាត់បង់តាំងពីទសវត្សរ៍មុនមកម្ល៉េះ។ ចំពោះដែនជម្រកសត្វព្រៃភ្នំឌ៉ាល់ និងឧទ្យានជាតិព្រះមុនីវង្សបូកគោ ពុំទាន់មានការបញ្ជាក់អះអាងសាឡើងវិញនៅឡើយទេ ថាតើមានដំរីនៅសេសសល់ក្នុងតំបន់ទាំងពីរនេះ ឬក៏បានបាត់បង់ទៅហើយ (សូមមើលរូបភាពទី១)។

រូបភាពទី១ ផែនទីរបាយ ជម្លោះ និងផែនជម្រកដំរីព្រៃនៅកម្ពុជា



១.២ បញ្ហាអាទិភាព

១.២.១ ការបាត់បង់ និងការបែកខ្ញែកទីជម្រក

ដំរីព្រៃត្រូវការទីជម្រកជាប់ៗគ្នាអប្បបរមាប្រមាណជា ៤ ៤០០គីឡូម៉ែត្រការ៉េ ដើម្បីរស់នៅឱ្យបានយូរអង្វែង និងគង់វង្ស។ ដំរីព្រៃដែលមានវត្តមាននៅកម្ពុជាបច្ចុប្បន្នកំពុងរស់នៅក្នុងទីជម្រកជាច់ដោយឡែកៗពីគ្នា ដោយសារកត្តាមួយចំនួនដូចជាការបម្លែងពីដីព្រៃទៅជាដីកសិកម្ម ទាំងខ្នាតតូច និងធំ ការតាំងទីលំនៅ ការកសាងហេដ្ឋារចនាសម្ព័ន្ធថ្មីៗ និងតម្រូវការផ្នែកអភិវឌ្ឍន៍ផ្សេងៗទៀតជាដើម។

ដោយមានតម្រូវការផ្នែកអភិវឌ្ឍន៍ តំបន់ដីទំនាបនៃជួរភ្នំក្រវាញបានប្រែក្លាយទៅជាតំបន់អភិវឌ្ឍន៍ធំៗមួយចំនួនដូចជាទំបន់វារីអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ គម្រោងទាំងនេះ បានធ្វើឱ្យហ្វូងដំរីព្រៃដែលកំពុងរស់នៅក្នុងទីជម្រកសំខាន់ធំៗ រត់គេចទៅរស់នៅតាមទីជម្រកតូចៗដាច់ពីគ្នា។ ចរាចរណ៍នៅលើផ្លូវជាតិលេខ៤ពីភ្នំពេញទៅខេត្តព្រះសីហនុបានបណ្តាលឱ្យមានការកាត់ផ្តាច់ចលនាផ្លាស់ទីទៅមករបស់ដំរីព្រៃរវាងឧទ្យានជាតិព្រះមុនីវង្សបូកគោនិងឧទ្យានជាតិព្រះសុរាម្រិត-កុសុម:(គិរីរម្យ)។ លើសពីនេះទៀត ការតាំងទីលំនៅ និងការអភិវឌ្ឍនៅតាមបណ្តោយផ្លូវជាតិលេខ៤ ការទន្ទ្រានចូលទៅក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសុម:(គិរីរម្យ) និងតំបន់ព្រៃនៅជិតខាងពីសំណាក់ប្រជាជនក៏បានបណ្តាលឱ្យបាត់បង់ទីជម្រកសត្វដំរីព្រៃនៅតំបន់នេះផងដែរ។ គម្រោងអភិវឌ្ឍន៍ណាមួយនៅតាមបណ្តោយដងស្ទឹងស្រែអំបិលអាចនឹងធ្វើឱ្យមានការគំរាមកំហែងដល់ហ្វូងដំរីព្រៃដែលកំពុងរស់នៅចន្លោះតំបន់ដីជាតនិងឧទ្យានជាតិព្រះសុរាម្រិត-កុសុម:(គិរីរម្យ)។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពីវាលពីរ(ជាប់ផ្លូវជាតិលេខ៤៨)ទៅថ្មបាំង រួមនឹងការកើនឡើងនៃការតាំងទីលំនៅថ្មីៗនៅវាលពីរ ដែលស្ថិតនៅក្នុងទីជម្រកដ៏សំខាន់សម្រាប់ដំរីព្រៃក្នុងតំបន់ជួរភ្នំក្រវាញខាងត្បូងអាចជាការរំខានមួយទៀតដល់ការរស់នៅ និងការផ្លាស់ទីរបស់ពួកវា។ សកម្មភាពចរាចរណ៍លើផ្លូវជាតិលេខ៤៨ ពីស្រែអំបិលទៅខេត្តកោះកុងនៅត្រង់ចំណុចគីឡូម៉ែត្រលេខ១០៥ ទំនងជាបង្កការរំខានដល់ចលនាផ្លាស់ទីរបស់ដំរីព្រៃដែរ។ ការសិក្សានាពេលថ្មីៗនេះបានបង្ហាញថា ដំរីព្រៃជៀសវាងការដើរឆ្លងកាត់ផ្លូវ មានន័យថា ច្រករបៀងដែលដំរីព្រៃធ្លាប់ឆ្លងកាត់ពីមុនអាចត្រូវបានកាត់ផ្តាច់ដោយសារផ្លូវ ធ្វើឱ្យហ្វូងដំរីបែកខ្ញែក និងទៅរស់នៅក្នុងទីតាំងដាច់ពីគ្នា។ ការតាំងទីលំនៅរបស់ប្រជាជននិងតម្រូវការសម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ទំនាបនៃដែនជម្រកសត្វព្រៃភ្នំសំកុសបានធ្វើឱ្យបាត់បង់ដែនជម្រកដំរីព្រៃគួរឱ្យកត់សម្គាល់។ ផែនការអភិវឌ្ឍផ្លូវលេខ៥៦

ពីវាលវែងទៅថ្មដា និងផ្លូវទៅអូរសោម ដែលស្ថិតក្នុងភាគខាងកើតនៃដែនជម្រកសត្វព្រៃភ្នំសំកុស បានធ្វើឱ្យមានការបែកខ្ទែកហ្វូងដំរីព្រៃក្នុងដែនជម្រកនេះ។ ដែនជម្រកសត្វព្រៃ«ព្រៃឡង់»ត្រូវបានកាត់ផ្តាច់ពីដែនជម្រកសត្វព្រៃឆែបដោយសារការបម្លែងពីដីព្រៃជាដីកសិកម្ម ការតាំងទីលំនៅរបស់ប្រជាជននៅតាមដងផ្លូវពីស្ទឹងត្រែងទៅព្រះវិហារ និងសម្បទានដីសេដ្ឋកិច្ចនៅចន្លោះតំបន់ទាំងពីរ។ ដូច្នេះ ហ្វូងដំរីព្រៃនៅដែនជម្រកសត្វព្រៃ«ព្រៃឡង់»ត្រូវបានកាត់ផ្តាច់ពីហ្វូងដំរីព្រៃនៃដែនជម្រកសត្វព្រៃឆែប។

តំបន់ទេសភាពខ្ពង់រាបភាគខាងកើតមានតំបន់ការពារធម្មជាតិចំនួនប្រាំបួនតជាប់គ្នារវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម (តំបន់ការពារធម្មជាតិចំនួន៦កន្លែងក្នុងប្រទេសកម្ពុជា និងតំបន់ការពារធម្មជាតិចំនួន៣កន្លែងក្នុងប្រទេសវៀតណាម)។ នៅចុងឦសានប្រទេស ដំរីព្រៃនៅក្នុងឧទ្យានជាតិរ៉ៃ:ដ័យក្នុងប្រទេសកម្ពុជាទំនងជាផ្លាស់ទីទៅមកទៅកាន់ព្រៃក្នុងខេត្តអ័ត្ត:ពើប្រទេសឡាវ។ ភាពតភ្ជាប់គ្នារបស់តំបន់ទាំងអស់នេះត្រូវបានកាត់ផ្តាច់បន្តិចម្តងៗ និងវាទាមទារឱ្យមានការសហការតាមព្រំដែនក្នុងការអភិរក្សដំរីអាស៊ីក្នុងតំបន់ទាំងនោះ។

ក្រៅពីនេះ តម្រូវការផ្នែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការពង្រីកផ្លូវចាស់ ការសាងសង់ផ្លូវថ្មី និងការកើនឡើងនូវកម្រិតនៃការធ្វើចរាចរណ៍ឆ្លងកាត់ទីជម្រកដ៏សំខាន់សម្រាប់ដំរីព្រៃ ក៏ជាមូលហេតុដែលនាំឱ្យមានការថយចុះ និងកាត់ផ្តាច់ទីជម្រក ព្រមទាំងកាត់ផ្តាច់ច្រករបៀងសម្រាប់ផ្លាស់ទី ដូចជាផ្លូវជាតិលេខ៧៦ បានកាត់តាមភាគខាងលិចនៃដែនជម្រកសត្វព្រៃស្រែពកនៅតំបន់ខ្ពង់រាបភាគខាងកើតក្នុងខេត្តមណ្ឌលគិរី។

១.២.២ ជម្លោះរវាងមនុស្ស និងដំរី

ជម្លោះរវាងមនុស្ស និងដំរីព្រៃបានបង្កផលអវិជ្ជមានជាច្រើន។ ការទទួលរងនូវភាពតានតឹងអាចបណ្តាលឱ្យដំរីព្រៃមានបញ្ហាជាច្រើនចំពោះសុខភាពរបស់វាដូច

ជាការកើនឡើងនូវការផ្ទុកបរាសិត(Hing 2012)។ ការផ្លាស់ទី ទាំងចម្ងាយជិត ទាំងចម្ងាយធ្ងាយតាមរដូវ និងការស្វែងរកចំណី អាចរងការរំខានដោយសារវត្តមានរបស់មនុស្ស។ លើសពីនេះទៀត ដំរីព្រៃអាចទទួលរងការវាយតបពីសំណាក់ប្រជាជនរហូតដល់រងរបួស ឬឈានដល់ការសម្លាប់ ជាការសងសឹកនឹងដំរីព្រៃដែលបានស៊ីដំណាំរបស់ពួកគេ។

ជម្លោះរវាងមនុស្ស និងដំរីព្រៃក៏ធ្វើឱ្យមានផលប៉ះពាល់ផងដែរដល់ប្រជាពលរដ្ឋតាមរយៈការបំផ្លាញដំណាំ ផ្ទះសំបែង ទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងអាចឈានទៅដល់មានរបួសស្នាម ឬស្លាប់នៅពេលមនុស្សតទល់ប្រឈមជាមួយនឹងដំរីព្រៃដោយផ្ទាល់។ មូលហេតុចម្បងនៃការកើតជម្លោះរវាងមនុស្ស និងដំរីព្រៃ គឺបណ្តាលមកពីការទន្ទ្រានយកដីព្រៃក្នុងដែនជម្រក និងច្រករបៀងដែលសត្វដំរីព្រៃធ្លាប់ឆ្លងកាត់។ ជម្លោះរវាងមនុស្ស និងដំរីព្រៃបានកើតញឹកញាប់បំផុតនៅក្នុងតំបន់ជ្រលងពេជ្រនិល ភាគខាងកើត និងខាងត្បូងនៃឧទ្យានជាតិព្រះសុរាម្រិត-កុសុម: (គិរីរម្យ) តាមជើងភ្នំគិរីរម្យក្នុងខេត្តកំពង់ស្ពឺ និងតំបន់ថ្មរួងខេត្តព្រះសីហនុ។ វាក៏កើតឡើងញឹកញាប់ក្នុងតំបន់អារ៉ែង ភូមិសាស្ត្រភូមិព្រៃកស្វាយ ឃុំថ្មដូនពៅ ស្រុកថ្មបាំង នៃឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង និងភូមិព្រៃកស្ទាប់ក្នុងឧទ្យានជាតិបុទុមសាគរខេត្តកោះកុង។ ក្រៅពីនេះ ជម្លោះរវាងមនុស្ស និងដំរីព្រៃបានកើតឡើងក្នុងដែនជម្រកសត្វព្រៃ«ព្រៃឡង់»ក្នុងភូមិសាស្ត្រខេត្តក្រចេះ និងនៅតំបន់ដែនជម្រកសត្វព្រៃកែវសីមាខេត្តមណ្ឌលគិរី។ នៅតំបន់ទេសភាពខ្ពង់រាបភាគខាងកើត ជម្លោះរវាងមនុស្ស និងដំរីព្រៃបានកើតឡើងជាញឹកញាប់ និងកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ជាពិសេសនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា(សូមមើលរូបភាពទី១)។ យើងបានផ្តល់ការគាំទ្រសហគមន៍មូលដ្ឋានក្នុងការបន្ធូរបន្ថយជម្លោះដោយទទួលបានជោគជ័យដូចជាតាមរយៈការរាយការណ៍

ពីសហគមន៍ និងគ្មានការសងសឹកធ្វើឱ្យដំរីព្រៃរងរបួស ឬស្លាប់នោះទេ។ យុទ្ធសាស្ត្រដែលល្អ និងប្រកបដោយនិរន្តរភាពសម្រាប់ការដោះស្រាយជម្លោះ គឺការបណ្តុះបណ្តាលបច្ចេកទេសបន្ទូរបន្ថយជម្លោះដល់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ទាំងនេះ។

១.២.៣ ការបរបាញ់

ការបរបាញ់ក្នុងអំឡុងពេលជាង៣០ឆ្នាំចុងក្រោយនេះ បានសម្លាប់ដំរីព្រៃនៅប្រទេសកម្ពុជាអស់ជាច្រើនក្បាល។ ប៉ុន្តែកម្រិតនៃការបរបាញ់នេះបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ដោយសារតែមានការពង្រឹងការអនុវត្តច្បាប់។ នៅក្នុងតំបន់ជួរភ្នំក្រវ៉ាញ មិនមានរបាយការណ៍ណាមួយស្តីពីឧបទ្ទវហេតុនៃការបរបាញ់សត្វដំរីព្រៃខុសច្បាប់ចាប់តាំងពីឆ្នាំ២០០៣មកម្ល៉េះ។ នៅក្នុងតំបន់ទេសភាពខ្ពង់រាបភាគខាងកើត ការស្លាប់របស់ដំរីចំនួន៨ក្បាលអាចមានការពាក់ព័ន្ធនឹងការបរបាញ់។ តាមរបាយការណ៍ពីប្រជាពលរដ្ឋ ការសម្លាប់ដំរីព្រៃអាចបណ្តាលមកពីតម្រូវការចម្បងគឺភ្លុក និងកន្ទុយ។ ការរកឃើញ និងការកត់ត្រាពីការសម្លាប់ដំរីព្រៃនៅតំបន់ទាំងនោះអាចមានចំនួនទាបជាងចំនួនសម្លាប់ពិតប្រាកដ ដោយសារក្រុមអនុវត្តច្បាប់ និងក្រុមល្បាតដោយសហគមន៍មានចំនួនតិច ចំណែកឯការបរបាញ់អាចកើតមាននៅលើផ្ទៃដីដ៏ធំធេង និងនៅក្នុងតំបន់ព្រៃជ្រៅៗ។ ការបរបាញ់ និងការជួញដូរសត្វព្រៃខុសច្បាប់នៅក្នុងខេត្តមណ្ឌលគិរីនៅតែជាបញ្ហាអាទិភាពសម្រាប់ពង្រឹងសកម្មភាពអន្តរាគមន៍ និងគ្រប់គ្រងជាបន្ទាន់។ ក្រៅពីនេះ ការជួសជុល និងកសាងផ្លូវនៅក្នុងខេត្ត និងតាមបណ្តោយព្រំដែនអន្តរជាតិខ្មែរ-វៀតណាមជាយុទ្ធសាស្ត្រការពារបូរណភាពទឹកដីរបស់រដ្ឋាភិបាលតែវាអាចបណ្តាលឱ្យមានការកើនឡើងនៃសកម្មភាពបរបាញ់ខុសច្បាប់ដោយសារមានការកើនឡើងនូវផ្លូវលំតូចៗ ប្រសិនបើមិនមានវិធានការទុកជាមុននោះទេ។

ការសិក្សាអំពីតម្រូវការក្លុកដំរីអាស៊ីនៅតាមទីផ្សារក្នុងទីក្រុងភ្នំពេញ និងសៀមរាប

បានឱ្យដឹងថាមានជនជាតិចិន វៀតណាម ខ្មែរ និងជាតិសាសន៍ដទៃទៀតបានចូលទិញសម្ភារៈធ្វើពីក្លុក និងផ្នែកផ្សេងទៀតនៃសារពាង្គកាយសត្វដំរី។ ដោយមានតម្រូវការនៅលើទីផ្សារ អ្នកជំនួញបរទេសមួយចំនួនអាចនឹងមកកម្ពុជាក្នុងគោលបំណងទិញក្លុកដំរី ឬរបស់របរផ្សេងទៀតធ្វើពីសារពាង្គកាយដំរីដើម្បីធ្វើពាណិជ្ជកម្មខុសច្បាប់នៅក្នុងប្រទេសរបស់គេ។ នេះជាមូលហេតុអាចនាំឱ្យមានការនាំចូលក្លុក និងសារពាង្គកាយដំរីពីក្រៅប្រទេស ព្រមទាំងអាចឈានដល់ការសម្លាប់ដំរីអាស៊ីក្នុងស្រុកដើម្បីយកក្លុក និងផ្នែកផ្សេងៗទៀតនៃខ្លួនដំរីសម្រាប់បំពេញតម្រូវការទាំងនេះ។

យោងតាមលទ្ធផលពីការបំពាក់ម៉ាស៊ីនថតស្វ័យប្រវត្តនៅក្នុងឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូងថ្មីៗនេះ ក្នុងចំណោមកូនដំរីព្រៃចំនួន៧ក្បាល មាន៤ក្បាលហើយដែលមានអន្ទាក់នៅជាប់នឹងជើងរបស់ពួកវា ហើយក៏មានកូនដំរីព្រៃ១ក្បាលដែរដែលបានស្លាប់ដោយសារអន្ទាក់។ ភស្តុតាងនេះបានបញ្ជាក់ថា ការប្រើប្រាស់អន្ទាក់សម្រាប់ចាប់សត្វព្រៃនៅក្នុងប្រទេសកម្ពុជាជាបញ្ហាដ៏គ្រោះថ្នាក់បំផុតចំពោះដំរីអាស៊ីពីព្រោះវាអាចបណ្តាលឱ្យដំរីរងរបួស និងស្លាប់បាន។ ដោយសាររយៈពេលនៃការបន្តពូជរបស់ដំរីអាស៊ីយឺត(ប្រាំឆ្នាំកើតបានកូនមួយ) បើសិនជាអត្រាស្លាប់នៃកូនដំរីព្រៃខ្ពស់ដោយសារតែរងរបួសពីអន្ទាក់ នោះចំនួនដំរីព្រៃនៅកម្ពុជាអាចមានបញ្ហាប្រឈមខ្ពស់ក្នុងការផុតពូជ។

១.២.៤ ការចាប់ដំរីព្រៃមកចិញ្ចឹម

បច្ចុប្បន្ននេះ ការទាក់ចាប់ដំរីព្រៃយកមកចិញ្ចឹម គឺជាករណីកម្រមានណាស់នៅក្នុងប្រទេសកម្ពុជា ហើយសកម្មភាពនេះក៏ត្រូវបានចាត់ទុកជាទង្វើខុសច្បាប់ផងដែរ។ វាមានទីផ្សារសម្រាប់វិស័យទេសចរណ៍ដែលផ្អែកលើដំរីស្រុក (ឧ.៖ ការជិះដំរីកម្សាន្តសម្រាប់ទេសចរណ៍)។ ចំនួនដំរីស្រុកនៅក្នុងប្រទេសកម្ពុជាមានចំនួនប្រមាណ

ជា៧១ភាគ ហើយដំរីស្រុកទាំងនេះកាន់តែចាស់ទៅៗ និងមិនមានកម្មវិធីបង្កាត់ពូជទេ។ ដូច្នេះសកម្មភាពទាំងនេះនឹងបង្កឱ្យមានការកើនឡើងនូវហានិភ័យនៃការទាក់ចាប់ដំរីព្រៃមកចិញ្ចឹមក្នុងទសវត្សរ៍ក្រោយៗ ប្រសិនបើមិនចាប់ផ្តើមមានវិធានការក្នុងពេលនេះទេ។ បច្ចុប្បន្ន ដំរីព្រៃនៅក្នុងប្រទេសកម្ពុជាមានចំនួនតិចណាស់ ហើយប្រសិនបើមានការចាប់ណាមួយ នោះវាពិតជានាំឱ្យមានផលវិបាកជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរជាមិនខាន។ ម្យ៉ាងវិញទៀត គេគួរពិនិត្យ និងពង្រឹងច្បាប់ពីការនាំចូលដំរីស្រុកពីប្រទេសជិតខាងមកក្នុងប្រទេសកម្ពុជាផងដែរ។

១.២.៥ ហ្វូងដំរីព្រៃមានចំនួនតិច

ដំរីព្រៃមានចំនួនតិចតួច ឯការកាត់ផ្តាច់ទីជម្រកមានកម្រិតខ្ពស់ ធ្វើឱ្យដំរីព្រៃនៅកម្ពុជាងាយនឹងទទួលរងគ្រោះយ៉ាងខ្លាំង អាចឈានទៅដល់ការផុតពូជដោយសារតែការរស់នៅរប៉ាត់រប៉ាយ បែកខ្ទែកគ្នា និងការបាត់បង់សេនេទិចចម្រុះ(ដែលនាំឱ្យមានការថយចុះនូវអត្រាបង្កកំណើត និងភាពធន់នឹងជំងឺផ្សេងៗ)។

១.២.៦ ការរំខានដោយមនុស្ស

សកម្មភាពមួយចំនួនរបស់មនុស្សបានរំខានដល់ទីជម្រកសំខាន់ៗរបស់ដំរីព្រៃ ហើយពួកវាអាចងាយទទួលរងការរំខានពីមនុស្ស និងគេចចេញពីមនុស្ស។ វត្តមាន និងសកម្មភាពរបស់មនុស្សអាចនាំឱ្យដំរីព្រៃមិនប្រើប្រាស់តំបន់ជាក់លាក់ណាមួយ ដែលអាចធ្វើឱ្យហ្វូងរបស់ពួកវារស់នៅដាច់ពីគ្នា។ ការតាំងទីលំនៅ និងចរាចរណ៍មមាញឹកនៅតាមបណ្តោយផ្លូវជាតិលេខ៤ និងលេខ៤៨ បានធ្វើឱ្យដំរីព្រៃមិនអាចឆ្លងកាត់បានទេ។ កត្តាទាំងនេះបានកម្រិតលទ្ធភាពរបស់ដំរីព្រៃទាំងនោះក្នុងការផ្លាស់ទី និងស្វែងរកដៃគូរបស់ពួកវា។ តំបន់ផ្សេងៗទៀតដូចជាច្រករបៀងសំខាន់មួយក្នុងស្រុកស្រែអំបិលអាចត្រូវបានប្រើប្រាស់យ៉ាងសកម្មដោយសកម្មភាពកាប់ឈើល្មើសច្បាប់ ការប្រមូល

អនុផលព្រៃឈើ និងការបរបាញ់ ជាមូលហេតុធ្វើឱ្យសត្វដំរីព្រៃបញ្ឈប់ការប្រើប្រាស់ច្រករបៀងនេះទាំងស្រុង។ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធធំៗក៏អាចរំខាន និងធ្វើឱ្យដំរីព្រៃខ្វះទីជម្រកផងដែរ។

ការកសាងផ្លូវថ្នល់ថ្មីៗ និងការជួសជុលផ្លូវចាស់ឡើងវិញនៅតាមតំបន់ខ្ពង់រាបភាគខាងកើត គឺជាកត្តាមួយរួមចំណែកកាត់ផ្តាច់ទីជម្រក និងរំខានដល់ដំរីព្រៃ។ នៅក្នុងតំបន់ដែនជម្រកសត្វព្រៃកែវសីមាខេត្តមណ្ឌលគិរី មានចរាចរណ៍មមាញឹកយ៉ាងខ្លាំងនៅតាមដងផ្លូវលេខ ៧៦ ដែលឆ្លងកាត់ទីជម្រកដ៏សំខាន់សម្រាប់ដំរីព្រៃនៃដែនជម្រកសត្វព្រៃ។ ដូចគ្នានេះដែរ ការកើនឡើងចរាចរណ៍នៅតាមផ្លូវជាតិលេខ ៧៦A បានធ្វើឱ្យបែកខ្ទេកហ្វូងដំរីព្រៃដែលធ្លាប់ផ្លាស់ទីរវាងដែនជម្រកសត្វព្រៃភ្នំព្រេច និងដែនជម្រកសត្វព្រៃស្រែពក។ ដូច្នេះ ការកើនឡើងនៃការធ្វើចរាចរណ៍ សំលេង និងរំញ័រពីផ្លូវសំខាន់ៗទាំងនេះទំនងជាបង្កផលប៉ះពាល់ដល់ការផ្លាស់ទីរបស់ដំរីព្រៃ។ លើសពីនេះទៀត ការកើនឡើងនៃអ្នកចំណូលថ្មីទូទាំងខេត្តបានបណ្តាលឱ្យមានការកើនឡើងនៃការរានដីព្រៃ ការកាប់ឈើ និងការបរបាញ់ខុសច្បាប់។ ការកាប់ឈើ និងការបរបាញ់ខុសច្បាប់នៅក្នុងតំបន់ការពារធម្មជាតិទំនងជាមូលហេតុដ៏ចម្បងមួយទៀតចំពោះដំរីព្រៃនៅក្នុងតំបន់ភូមិភាគខាងកើត។ បញ្ហានេះគឺកើតឡើងនៅភាគខាងត្បូងនៃផ្លូវជាតិលេខ ៧៦ និងតំបន់ជាប់ព្រំដែនអន្តរជាតិជាមួយប្រទេសវៀតណាម ដែលបណ្តាលឱ្យដំរីព្រៃផ្លាស់ទីទៅភាគខាងជើងនៃដែនជម្រកសត្វព្រៃកែវសីមា ព្រោះជាតំបន់ដែលមានការរំខានតិច។ មិនតែប៉ុណ្ណោះ ភស្តុតាងថ្មីពីប្រជាពលរដ្ឋនៅឆ្នាំ២០១៥ បានបង្ហាញថា ការផ្លាស់ទីទំនងជាមានការផ្លាស់ប្តូរនៅក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច និងដែនជម្រកសត្វព្រៃស្រែពក ដោយសារតែការកើនឡើងនូវសកម្មភាពល្មើសច្បាប់នៅក្នុងទីជម្រកសំខាន់សម្រាប់ដំរីព្រៃ។

២. យុទ្ធសាស្ត្រ និងការវិភាគយុទ្ធសាស្ត្រ

ផែនការសកម្មភាពអភិរក្សដំរីអាស៊ីរយៈពេល១០ឆ្នាំ(២០២០-២០២៩)នេះ មានគោលដៅបង្កើតក្របខ័ណ្ឌគោលនយោបាយ និងយន្តការគ្រប់គ្រងមួយដោយរួមបញ្ចូលភាគីពាក់ព័ន្ធ ដើម្បីកាត់បន្ថយការគំរាមកំហែងទៅលើដំរីអាស៊ីនៅកម្ពុជា។ ផែនការសកម្មភាពអភិរក្សនេះមានសកម្មភាពយុទ្ធសាស្ត្រចំនួន៧ ដូចខាងក្រោម៖

- សកម្មភាពយុទ្ធសាស្ត្រទី១៖ កាត់បន្ថយការបាត់បង់ទីជម្រក
- សកម្មភាពយុទ្ធសាស្ត្រទី២៖ អភិរក្ស និងតភ្ជាប់ច្រករបៀង និងហ្វូងដំរីព្រៃឡើងវិញ
- សកម្មភាពយុទ្ធសាស្ត្រទី៣៖ ពង្រឹងការអនុវត្តច្បាប់
- សកម្មភាពយុទ្ធសាស្ត្រទី៤៖ បង្ការមិនឱ្យមានការចាប់ដំរីព្រៃមកចិញ្ចឹម
- សកម្មភាពយុទ្ធសាស្ត្រទី៥៖ បន្ធូរបន្ថយជម្លោះរវាងមនុស្ស និងដំរីព្រៃ
- សកម្មភាពយុទ្ធសាស្ត្រទី៦៖ អប់រំផ្សព្វផ្សាយ
- សកម្មភាពយុទ្ធសាស្ត្រទី៧៖ សិក្សាស្រាវជ្រាវនិងតាមដានត្រួតពិនិត្យចំនួនដំរីអាស៊ី

រាជរដ្ឋាភិបាលកម្ពុជា បានប្រគល់ភារកិច្ចឱ្យក្រសួងបរិស្ថានដើម្បីដឹកនាំការគ្រប់គ្រងការការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។ អនុក្រឹតលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ត្រូវបានរៀបចំឡើងជាថ្មីក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃការកិច្ចរបស់ខ្លួន។

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ ក៏ជាឯកសារគោលមួយបន្ថែមផងដែរសម្រាប់ជួយជំរុញដល់ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ការពារធម្មជាតិ

កម្ពុជាឱ្យមានប្រសិទ្ធភាព ពិសេសជួយដំរុញដល់ការប្រើប្រាស់ឱ្យស្របតាមថ្នាក់ IUCN និងប្រព័ន្ធគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗដើម្បីធានាការការពារឱ្យបានត្រឹមត្រូវនូវតំបន់ដែលមានតម្លៃអភិរក្សខ្ពស់ និងបង្កើនការចូលរួម និងផ្តល់ផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

ច្បាប់ជាច្រើនទៀតក៏មានឥទ្ធិពលដល់ការគ្រប់គ្រង និងអភិរក្សដំរីអាស៊ីនៅកម្ពុជាដែរ ដូចជាច្បាប់ស្តីពីព្រៃឈើ(២០០២) ច្បាប់ភូមិបាល(២០០១) ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ(១៩៩៦)។ ក្រៅពីនេះ ប្រទេសកម្ពុជាជាប្រទេសហត្ថលេខីនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្ត និងរុក្ខជាតិព្រៃកំពុងរងគ្រោះថ្នាក់(សាយតេស) អនុសញ្ញាជីវៈចម្រុះ និងអនុសញ្ញាប្រែប្រួលអាកាសធាតុ ដែលកម្ពុជាបានបង្ហាញពីការតាំងចិត្តក្នុងការអភិរក្សជីវៈចម្រុះរបស់ខ្លួនឱ្យបានគង់វង្ស។ អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ(IUCN)បានចុះបញ្ជីដំរីអាស៊ីក្នុងក្រុមប្រភេទសត្វដែលកំពុងរងគ្រោះជិតផុតពូជ(EN) និងនៅក្រោមអនុសញ្ញាសាយតេស ដំរីអាស៊ីត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឧបសម្ព័ន្ធI។ ដូច្នេះ ផែនការសកម្មភាពអភិរក្សដំរីអាស៊ីនៅកម្ពុជានេះជាឯកសារមួយក្នុងចំណោមឯកសារជាច្រើនទៀត(ដូចជា យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ ជាដើម)ដែលអាចបង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រដើម្បីការពារ និងអភិរក្សប្រភេទទទួលរងការគំរាមកំហែង ដើម្បីឱ្យឆ្លើយតបទៅនឹងច្បាប់ជាតិ ច្បាប់អន្តរជាតិ និងអនុសញ្ញានានា។

៣. ផែនការសកម្មភាពយុទ្ធសាស្ត្រ

៣.១ ផែនការសកម្មភាពយុទ្ធសាស្ត្រទី១៖ កាត់បន្ថយការបាត់បង់ទីជម្រក

សកម្មភាពអាទិភាពនៃសកម្មភាពយុទ្ធសាស្ត្រនេះ រួមមាន៖

១. បង្កើតផែនការប្រើប្រាស់ដី និងបែងចែកតំបន់ក្នុង ឬជុំវិញ តំបន់ការពារធម្មជាតិ និងរបៀងអភិរក្សដីវៈចម្រុះអាស្រ័យទៅតាមតម្រូវការទីជម្រកសំខាន់ៗសម្រាប់ដំរីព្រៃ

២. កំណត់ព្រំប្រទល់ប្រព័ន្ធតំបន់ការពារធម្មជាតិ និងតំបន់សំខាន់ៗសម្រាប់អភិរក្សដំរីព្រៃ

៣. រៀបចំផែនការគ្រប់គ្រង និងប្រតិបត្តិ

៤. ពង្រឹងការអនុវត្តច្បាប់

៥. លើកស្ទួយជីវភាពសហគមន៍មូលដ្ឋាន

លទ្ធផលរំពឹងទុកក្នុងពេលអនុវត្តសកម្មភាពអាទិភាពទាំងនេះ រួមមាន៖

១. រៀបចំផែនទី និងផែនការគ្រប់គ្រង

២. បោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិ និងរបៀងអភិរក្សដីវៈចម្រុះ

៣. អនុម័ត និងតាមដានការអនុវត្តផែនការគ្រប់គ្រង

៣.២ ផែនការសកម្មភាពយុទ្ធសាស្ត្រទី២៖ អភិរក្ស និងតភ្ជាប់ច្រករបៀង និងហ្វូងដំរីព្រៃឡើងវិញ

សកម្មភាពអាទិភាពនៃសកម្មភាពយុទ្ធសាស្ត្រនេះ រួមមាន៖

១. កំណត់ទីតាំង អភិរក្ស និងការពារច្រករបៀងសំខាន់ៗ

២. បង្កើតច្រករបៀងថ្មី និងថែរក្សាច្រករបៀងចាស់សម្រាប់

តភ្ជាប់ទីជម្រក និងហ្វូងដំរីព្រៃផ្សេងៗគ្នាឡើងវិញ

៣. បង្កើនកិច្ចសហការតាមព្រំដែនជាមួយប្រទេសជិតខាង

៤. ផ្តល់យោបល់លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដោយគិតគូរពីតម្រូវការនៃការផ្លាស់ទីរបស់សត្វព្រៃ ជាពិសេសដំរីព្រៃ នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ

លទ្ធផលរំពឹងទុកក្នុងពេលអនុវត្តសកម្មភាពអាទិភាពទាំងនេះ រួមមាន៖

១. រៀបចំផែនការសម្រាប់ធ្វើការត្រួតពិនិត្យ និងតាមដានច្រករបៀងដំរីព្រៃ

២. រៀបចំផែនការគ្រប់គ្រងច្រករបៀងដំរីព្រៃ

៣. រៀបចំកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសជិតខាងសម្រាប់ការពារច្រករបៀងដំរីព្រៃ

៤. រៀបចំបញ្ចូលផែនការអភិរក្សដំរីព្រៃទៅក្នុងឯកសារវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA

៣.៣ ផែនការសកម្មភាពយុទ្ធសាស្ត្រទី៣៖ ពង្រឹងការអនុវត្តច្បាប់

សកម្មភាពអាទិភាពនៃសកម្មភាពយុទ្ធសាស្ត្រនេះ រួមមាន៖

១. ពង្រឹងការអនុវត្តច្បាប់ និងយាមល្បាតនៅតំបន់សំខាន់ៗ

២. កាត់បន្ថយតម្រូវការនៃការប្រើប្រាស់ផលិតផលធ្វើពីដំរីតាមរយៈការអប់រំផ្សព្វផ្សាយ

៣. ផ្សព្វផ្សាយច្បាប់ជាតិ និងអន្តរជាតិ

៤. ធ្វើកិច្ចសហការតាមព្រំដែនជាមួយប្រទេសជិតខាង

លទ្ធផលរំពឹងទុកក្នុងពេលអនុវត្តសកម្មភាពអាទិភាពទាំងនេះ រួមមាន៖

១. ផលិតឯកសារសម្រាប់អប់រំផ្សព្វផ្សាយ

២. រៀបចំផែនការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់
៣. ធ្វើបច្ចុប្បន្នភាពរបាយការណ៍ស្តីពីផលិតផលធ្វើអំពីសត្វដំរី
៤. ចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសជិតខាងស្តីពីការទប់ស្កាត់ការជួញដូរសត្វព្រៃ

៣.៤ ផែនការសកម្មភាពយុទ្ធសាស្ត្រទី៤៖ បង្ការមិនឱ្យមានការចាប់ដំរីព្រៃយកមកចិញ្ចឹម

សកម្មភាពអាទិភាពនៃសកម្មភាពយុទ្ធសាស្ត្រនេះ រួមមាន៖

១. ចុះបញ្ជីដំរីស្រុក និងមជ្ឈមណ្ឌលបង្កាត់ដំរីស្រុក
២. ចុះបញ្ជីដំរីស្រុកដែលបម្រើឱ្យវិស័យទេសចរណ៍
៣. ធ្វើយុទ្ធនាការយោសនាឱ្យក្រុមហ៊ុនទេសចរណ៍ទទួលខុសត្រូវចំពោះដំរីស្រុកដែលបម្រើឱ្យវិស័យទេសចរណ៍
៤. ពង្រឹងការអនុវត្តច្បាប់ដើម្បីទប់ស្កាត់ការចាប់ដំរីព្រៃមកចិញ្ចឹម

លទ្ធផលរំពឹងទុកក្នុងពេលអនុវត្តសកម្មភាពអាទិភាពទាំងនេះ រួមមាន៖

១. ចុះបញ្ជីដំរីស្រុក
២. ចុះកិច្ចព្រមព្រៀងជាមួយក្រសួងទេសចរណ៍លើប្រព័ន្ធគ្រប់គ្រងដំរីស្រុក
៣. គោលការណ៍ណែនាំស្តីពីការមិនឱ្យចាប់ដំរីព្រៃមកចិញ្ចឹម

៣.៥ ផែនការសកម្មភាពយុទ្ធសាស្ត្រទី៥៖ បន្ធូរបន្ថយជម្លោះរវាងមនុស្ស និងដំរីព្រៃ

សកម្មភាពអាទិភាពនៃសកម្មភាពយុទ្ធសាស្ត្រនេះ រួមមាន៖

១. គាំទ្រ និងបណ្តុះបណ្តាលសហគមន៍ក្នុងការបន្ធូរបន្ថយជម្លោះ រវាងមនុស្ស និងជំរំព្រៃ
២. ស្វែងរកបច្ចេកទេសថ្មីៗដើម្បីបន្ធូរបន្ថយជម្លោះ
៣. ទប់ស្កាត់ និងកាត់បន្ថយការធ្វើកសិកម្មនៅក្នុងទីជម្រកជំរំព្រៃ (ការទន្ទ្រានដីព្រៃ)
៤. លើកកម្ពស់ជីវភាពប្រជាជនមូលដ្ឋានដើម្បីកាត់បន្ថយការពឹងអាស្រ័យលើធនធានព្រៃឈើ

លទ្ធផលរំពឹងទុកក្នុងពេលអនុវត្តសកម្មភាពអាទិភាពទាំងនេះ រួមមាន៖

១. ចំនួនអ្នកបានបណ្តុះបណ្តាលពីបច្ចេកទេសថ្មីៗសម្រាប់ទប់ស្កាត់ និងកាត់បន្ថយជម្លោះរវាងមនុស្ស និងជំរំព្រៃ
២. ស្ថិតិផ្ទៃដីទីជម្រកជំរំព្រៃដែលរងការទន្ទ្រាន
៣. ផ្តល់បច្ចេកទេសថ្មីៗសម្រាប់លើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន

៣.៦ ផែនការសកម្មភាពយុទ្ធសាស្ត្រទី៦៖ អប់រំផ្សព្វផ្សាយ

សកម្មភាពអាទិភាពនៃសកម្មភាពយុទ្ធសាស្ត្រនេះ រួមមាន៖

១. រៀបចំ និងចែកចាយកម្មវិធីអប់រំ និងផ្សព្វផ្សាយ ព្រមទាំងសម្ភារៈសិក្សា
២. លើកស្ទួយការចែករំលែកព័ត៌មានរវាងស្ថាប័នជំនាញរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល

លទ្ធផលរំពឹងទុកក្នុងពេលអនុវត្តសកម្មភាពអាទិភាពទាំងនេះ រួមមាន៖

១. ផលិតឯកសារសម្រាប់អប់រំផ្សព្វផ្សាយ និងយុទ្ធនាការផ្សេងៗ
២. រៀបចំកិច្ចប្រជុំជាប្រចាំជាមួយអ្នកពាក់ព័ន្ធ

៣.៧ ផែនការសកម្មភាពយុទ្ធសាស្ត្រទី៧៖ សិក្សាស្រាវជ្រាវ និងតាមដានត្រួតពិនិត្យចំនួនដំរីព្រៃ

សកម្មភាពអាទិភាពនៃសកម្មភាពយុទ្ធសាស្ត្រនេះ រួមមាន៖

១. សិក្សាប៉ាន់ស្មានចំនួនដំរីព្រៃជារៀងរាល់៥ឆ្នាំម្តង

២. តាមដានត្រួតពិនិត្យកត្តាគំរាមកំហែង(កត់ត្រាករណីជម្លោះរវាងមនុស្ស និងដំរីព្រៃ ការបរបាញ់ ការបាត់បង់ទីជម្រក និងការធ្វើពាណិជ្ជកម្ម)

៣. សិក្សាបន្ថែមទៀតអំពីទំហំដែនជម្រក របាយ និងការប្រើប្រាស់ទីជម្រករបស់ដំរីព្រៃ

៤. សិក្សាពីលក្ខណៈអេកូឡូស៊ីរបស់ដំរីព្រៃ

៥. គណនាលទ្ធភាពនៃតំបន់ដែលអាចឱ្យដំរីព្រៃរស់នៅបាន

៦. តាមដាន និងវាយតម្លៃវិធីសាស្ត្របន្ធូរបន្ថយជម្លោះក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងៗដើម្បីឱ្យការគ្រប់គ្រងមានប្រសិទ្ធភាព

៧. រក្សាទិន្នន័យជាតិអំពីដំរីព្រៃស្លាប់ និងទិន្នន័យជម្លោះ

៨. សម្របសម្រួលក្នុងការសិក្សាស្រាវជ្រាវអំពីដំរីព្រៃជាមួយប្រទេសជិតខាង

លទ្ធផលរំពឹងទុកក្នុងពេលអនុវត្តសកម្មភាពអាទិភាពទាំងនេះ រួមមាន៖

១. ធ្វើបច្ចុប្បន្នភាពស្ថិតិដំរីព្រៃ

២. ធ្វើបច្ចុប្បន្នភាពផែនទីរបាយដំរីព្រៃនៅកម្ពុជា

៣. កំណត់តំបន់អាទិភាពសម្រាប់អភិរក្សដំរីព្រៃ

៤. កំណត់វិធីសាស្ត្រកាត់បន្ថយជម្លោះប្រកបដោយនិរន្តរភាព

តារាងផែនការសកម្មភាពអភិរក្សដំរីអាស៊ីនៅកម្ពុជា ២០២០-២០២៩

គោលបំណង និងសកម្មភាព	ស្ថាប័នអនុវត្ត	សូចនាករ	រយៈពេលអនុវត្ត
យុទ្ធសាស្ត្រទី១ៈ កាត់បន្ថយការបាត់បង់ទីជម្រក			
១.១ បង្កើតផែនការប្រើប្រាស់ដី និងបែងចែកតំបន់ក្នុង ឬជុំវិញតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះអាស្រ័យទៅតាមតម្រូវការទីជម្រកសំខាន់ៗសម្រាប់ដំរីព្រៃ	អកធ, មប, អករ	ផែនទីកំណត់តំបន់ និងផែនការគ្រប់គ្រងត្រូវបានកំណត់ដោយគិតពីទីជម្រកដំរីព្រៃ	ខ្លី
១.២ កំណត់ព្រំប្រទល់ប្រព័ន្ធតំបន់ការពារធម្មជាតិ និងតំបន់សំខាន់ៗសម្រាប់អភិរក្សដំរីព្រៃ	អកធ, មប, អករ	បោះបង្គោលព្រំប្រទល់តំបន់សំខាន់ៗ	ខ្លី
១.៣ រៀបចំផែនការគ្រប់គ្រង និងប្រតិបត្តិ	អកធ, មប, អករ	ការអនុវត្តផែនការគ្រប់គ្រងត្រូវបានតាមដាន និងវាយតម្លៃ	មធ្យម
១.៤ ពង្រឹងការអនុវត្តច្បាប់	អកធ, មប, អករ	ចំនួនបទល្មើស	រវែង
១.៥ លើកស្ទួយជីវភាពសហគមន៍មូលដ្ឋាន	អសម, មប, អករ	ជីវភាពសហគមន៍ត្រូវបានលើកកម្ពស់	រវែង
យុទ្ធសាស្ត្រទី២ៈ អភិរក្ស និងតភ្ជាប់ច្រករបៀង និងហ្វូងដំរីព្រៃឡើងវិញ			
២.១ កំណត់ទីតាំង អភិរក្ស និងការពារច្រករបៀងសំខាន់ៗ	អកធ, មប, អករ	តំបន់ច្រករបៀងត្រូវបានកំណត់និងការពារ	មធ្យម
២.២ បង្កើតច្រករបៀងថ្មី និងថែរក្សាច្រករបៀងចាស់សម្រាប់តភ្ជាប់ទីជម្រកនិងហ្វូងដំរីព្រៃផ្សេងៗគ្នាឡើងវិញ	អកធ, មប, អករ	តំបន់ច្រករបៀងចំនួន៤កន្លែងត្រូវបានបង្កើតឡើង	មធ្យម

គោលបំណង និងសកម្មភាព	ស្ថាប័នអនុវត្ត	សូចនាករ	រយៈពេលអនុវត្ត
២.៣ បង្កើនកិច្ចសហការតាមព្រំដែនជាមួយប្រទេសជិតខាងៈ ឡាវ (ឧទ្យានជាតិរីៈជ័យ) ថៃ (តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត) វៀតណាម (ដែនជម្រកសត្វព្រៃស្រែពក)	អកធ, មប, អករ	ចំនួនកិច្ចព្រមព្រៀងទ្វេភាគី	មធ្យម
២.៤ ផ្តល់យោបល់លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដោយគិតគូរពីតម្រូវការនៃការផ្លាស់ទីរបស់សត្វព្រៃ ជាពិសេសដំរីព្រៃ នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ	អកធ, មប, អករ, កសដ	ចំនួនគម្រោងរង្វាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមានដាក់បញ្ចូលដំណោះស្រាយជាក់លាក់សម្រាប់ការផ្លាស់ទីរបស់ដំរីព្រៃ	រៃង
យុទ្ធសាស្ត្រទី៣ៈ ពង្រឹងការអនុវត្តច្បាប់			
៣.១ ពង្រឹងការអនុវត្តច្បាប់ និងយាមល្បាតនៅតំបន់សំខាន់ៗ	អកធ, មប, អករ	ការរឹបអូស និងការអនុវត្តច្បាប់ត្រូវបានពង្រឹង	រៃង
៣.២ កាត់បន្ថយតម្រូវការនៃការប្រើប្រាស់ផលិតផលធ្វើពីដំរីតាមរយៈការផ្សព្វផ្សាយ	អកធ, មប, អករ	កាត់បន្ថយការប្រើប្រាស់ផលិតផលធ្វើពីដំរីបាន៦០%	រៃង
៣.៣ ផ្សព្វផ្សាយច្បាប់ជាតិ និងអន្តរជាតិ	អកធ, មប, អករ	បង្កើនការអប់រំផ្សព្វផ្សាយដល់សាធារណជនបាន៦០%	មធ្យម
៣.៤ ធ្វើកិច្ចសហការតាមព្រំដែនជាមួយប្រទេសជិតខាង	អកធ, មប, អករ	កិច្ចព្រមព្រៀងទ្វេភាគីត្រូវបានធ្វើឡើង	រៃង

គោលបំណង និងសកម្មភាព	ស្ថាប័នអនុវត្ត	សូចនាករ	រយៈពេលអនុវត្ត
យុទ្ធសាស្ត្រទី៤៖ បង្ការមិនឱ្យមានការចាប់ដំរីព្រៃយកមកចិញ្ចឹម			
៤.១ ចុះបញ្ជីដំរីស្រុក និងមជ្ឈមណ្ឌលបង្កាត់ដំរីស្រុក	អកធ, មប, អក, ក្រ.ទ	ដំរីស្រុក និងមជ្ឈមណ្ឌលបង្កាត់ដំរីស្រុកត្រូវបានចុះបញ្ជី	ខ្លី
៤.២ ចុះបញ្ជីដំរីស្រុកដែលបម្រើឱ្យវិស័យទេសចរណ៍	អកធ, មប, ក្រ.ទ, អក	ដំរីស្រុកដែលបម្រើក្នុងវិស័យទេសចរណ៍ត្រូវបានចុះបញ្ជី	មធ្យម
៤.៣ ធ្វើយុទ្ធនាការឃោសនាឱ្យក្រុមហ៊ុនទេសចរណ៍ទទួលខុសត្រូវចំពោះដំរីស្រុកដែលបម្រើឱ្យវិស័យទេសចរណ៍	អកធ, មប, ក្រ.ទ, អក	ឯកសារអប់រំផ្សព្វផ្សាយ និងយុទ្ធនាការ	ខ្លី
៤.៤ ពង្រឹងការអនុវត្តច្បាប់ដើម្បីទប់ស្កាត់ការចាប់ដំរីព្រៃមកចិញ្ចឹម	អកធ, មប, អក	របាយការណ៍រឹបអូសវត្ថុតាង និងឯកសារបណ្តឹងទៅតុលាការ	វែង
យុទ្ធសាស្ត្រទី៥៖ បន្ធូរបន្ថយជម្លោះរវាងមនុស្ស និងដំរីព្រៃ			
៥.១ គាំទ្រ និងបណ្តុះបណ្តាលសហគមន៍ក្នុងការបន្ធូរបន្ថយជម្លោះរវាងមនុស្ស និងដំរីព្រៃ	អកធ, មប, អក	បណ្តុះបណ្តាល និងគាំទ្រសហគមន៍ចំនួន ៧ កន្លែង	មធ្យម
៥.២ ស្វែងរកបច្ចេកទេសថ្មីៗ និងមាននិរន្តរភាពដើម្បីបន្ធូរបន្ថយជម្លោះ	អកធ, មប, អក	អនុវត្តសាកល្បងបច្ចេកទេសចំនួន ៥ ប្រភេទផ្សេងៗគ្នា	មធ្យម
៥.៣ ទប់ស្កាត់ និងកាត់បន្ថយការធ្វើកសិកម្មនៅក្នុងទីជម្រកដំរីព្រៃ(ការទន្ទ្រានដីព្រៃ)	អកធ, មប, អក	កាត់បន្ថយការទន្ទ្រានដីនៅដែនជម្រកដំរីព្រៃបាន ៨០%	វែង
៥.៤ លើកកម្ពស់ជីវភាពប្រជាជនមូលដ្ឋានដើម្បីកាត់បន្ថយការពឹងអាស្រ័យលើធនធានព្រៃឈើ	អសម, មប, អក	គម្រោងលើកកម្ពស់ជីវភាពប្រជាជនដោយមិនឱ្យមានការទន្ទ្រានដី	មធ្យម

គោលបំណង និងសកម្មភាព	ស្ថាប័នអនុវត្ត	សូចនាករ	រយៈពេលអនុវត្ត
យុទ្ធសាស្ត្រទី៦ៈ អប់រំផ្សព្វផ្សាយ			
៦.១ រៀបចំ និងចែកចាយកម្មវិធីអប់រំ និងផ្សព្វផ្សាយ ព្រមទាំងសម្ភារៈសិក្សា	អកធ, មប, អក	រៀបចំឯកសារអប់រំផ្សព្វផ្សាយ និងយុទ្ធនាការនានា	មធ្យម
៦.២ លើកស្ទួយការចែករំលែកព័ត៌មានរវាងស្ថាប័នជំនាញរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល	អកធ, មប, អក	ការប្រជុំ និងការទាក់ទងគ្នាជាប្រចាំរវាងអ្នកពាក់ព័ន្ធ	មធ្យម
យុទ្ធសាស្ត្រទី៧ៈ សិក្សាស្រាវជ្រាវ និងតាមដានត្រួតពិនិត្យចំនួនដំរីព្រៃ			
៧.១ សិក្សាប៉ាន់ស្មានចំនួនដំរីព្រៃជារៀងរាល់៥ឆ្នាំម្តង	អកធ, អក, ក្រ.អយក	របាយការណ៍ពីចំនួនដំរីព្រៃ	រវែង
៧.២ តាមដានត្រួតពិនិត្យកត្តាគំរាមកំហែង (កត់ត្រាករណីជម្លោះរវាងមនុស្ស និងដំរីព្រៃ ការបរបាញ់ ការបាត់បង់ទីជម្រក និងការធ្វើពាណិជ្ជកម្ម)	អកធ, មប, អក	របាយការណ៍តាមដាន និងកត់ត្រាជម្លោះរវាងមនុស្ស និងដំរីព្រៃ ការបរបាញ់ដំរីព្រៃ ការបាត់បង់ និងប្រើប្រាស់ទីជម្រក និងការប្រើប្រាស់ផលិតផលធ្វើពីដំរីព្រៃ	រវែង
៧.៣ សិក្សាបន្ថែមអំពីទំហំដែនជម្រក របាយ និងការប្រើប្រាស់ទីជម្រករបស់ដំរីព្រៃ	អកធ, មប, អក	របាយការណ៍វាយតម្លៃអំពីរ៉ាយ និងទីជម្រកដំរីព្រៃ	រវែង
៧.៤ សិក្សាពីលក្ខណៈអេកូឡូស៊ីរបស់ដំរីព្រៃ	អកធ, មប, អក	របាយការណ៍វាយតម្លៃអំពីលក្ខណៈអេកូឡូស៊ីរបស់ដំរីព្រៃ	រវែង
៧.៥ គណនាលទ្ធភាពនៃតំបន់ដែលអាចឱ្យដំរីព្រៃរស់នៅបាន	អកធ, មប, អក	របាយការណ៍សិក្សាលទ្ធភាពតំបន់ខ្ពង់រាបភាគខាងកើត និងជួរភ្នំក្រវាញ	មធ្យម

គោលបំណង និងសកម្មភាព	ស្ថាប័នអនុវត្ត	សូចនាករ	រយៈពេលអនុវត្ត
៧.៦ តាមដាន និងវាយតម្លៃវិធីសាស្ត្របន្ទូរបន្ថយជម្លោះរវាងមនុស្ស និងជំរឹព្រៃក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងៗដើម្បីឱ្យការគ្រប់គ្រងមានប្រសិទ្ធភាព	អកធ, មប, អការ	របាយការណ៍វាយតម្លៃវិធីសាស្ត្រថ្មីៗសម្រាប់បន្ទូរបន្ថយជម្លោះរវាងមនុស្ស និងជំរឹព្រៃ	រៃង
៧.៧ រក្សាទិន្នន័យជាតិអំពីជំរឹព្រៃស្លាប់ និងទិន្នន័យជម្លោះរវាងមនុស្ស និងជំរឹព្រៃ	អកធ, មប, អការ	រៀបចំប្រព័ន្ធទិន្នន័យជំរឹ និងជម្លោះរវាងមនុស្ស និងជំរឹព្រៃ	២០ឆ្នាំ
៧.៨ សម្របសម្រួលក្នុងការសិក្សាស្រាវជ្រាវអំពីជំរឹព្រៃជាមួយប្រទេសជិតខាង	អកធ, មប, អការ	កិច្ចព្រមព្រៀងទ្វេភាគី	មធ្យម

អកធ៖ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន, **អសម៖** អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន **មប៖** មន្ទីរបរិស្ថាន, **អការ៖** អង្គការមិនមែនរដ្ឋាភិបាល, **ក្រ.ទ៖** ក្រសួងទេសចរណ៍, **ក្រ.អយក៖** ក្រសួងអប់រំ យុវជន និងកីឬា, **កសជ៖** ក្រសួងសាធារណៈការ និងដឹកជញ្ជូន

៤. ធនធានហិរញ្ញវត្ថុ

គម្រោងថវិកាសម្រាប់ការអនុវត្តសកម្មភាពនៅក្នុងផែនការសកម្មភាពអភិរក្សដំរីអាស៊ីរយៈពេល១០ឆ្នាំ(២០២០-២០២៩) នេះមានប្រភពថវិកាមកពីការរួមបញ្ចូលទាំងកញ្ចប់ថវិការបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាដែលគ្រោងចំណាយថវិកាសរុបប្រមាណ ៤០,៥ លានដុល្លារសហរដ្ឋអាម៉េរិក។ តម្រូវការហិរញ្ញប្បទានទាំងអស់នេះគឺដើម្បីចំណាយលើការអនុវត្តកម្មវិធីនៃសកម្មភាពយុទ្ធសាស្ត្រទាំង ៧ ដែលបានកំណត់នៅក្នុងតារាងខាងលើ។ ក្នុងនោះ សកម្មភាពយុទ្ធសាស្ត្រទី ១ «កាត់បន្ថយការបាត់បង់ទីជម្រក» គ្រោងចំណាយថវិកាសរុបចំនួន ១១ លានដុល្លារសហរដ្ឋអាម៉េរិក។ សកម្មភាពយុទ្ធសាស្ត្រទី២ «អភិរក្ស និងតភ្ជាប់ច្រករបៀង និងហ្វូងដំរីព្រៃឡើងវិញ» គ្រោងចំណាយថវិកាសរុប ៤ លានដុល្លារសហរដ្ឋអាម៉េរិក។ សកម្មភាពយុទ្ធសាស្ត្រទី៣ «ពង្រឹងការអនុវត្តច្បាប់» គ្រោងចំណាយថវិកាសរុប ១០ លានដុល្លារសហរដ្ឋអាម៉េរិក។ សកម្មភាពយុទ្ធសាស្ត្រទី៤ «បង្ការមិនឱ្យមានការចាប់ដំរីព្រៃយកមកចិញ្ចឹម» គ្រោងចំណាយថវិកាសរុប ១០ លានដុល្លារសហរដ្ឋអាម៉េរិក។ សកម្មភាពយុទ្ធសាស្ត្រទី៥ «បន្ធូរបន្ថយជម្លោះរវាងមនុស្ស និងដំរីព្រៃ» គ្រោងចំណាយថវិការសរុបចំនួន ៣ លានដុល្លារសហរដ្ឋអាម៉េរិក។ សកម្មភាពយុទ្ធសាស្ត្រទី៦ «អប់រំផ្សព្វផ្សាយ» គ្រោងចំណាយថវិកាសរុបចំនួន ៥០០ ០០០ ដុល្លារសហរដ្ឋអាម៉េរិក។ សកម្មភាពយុទ្ធសាស្ត្រទី៧ «សិក្សាស្រាវជ្រាវ និងតាមដានត្រួតពិនិត្យចំនួនដំរីព្រៃ» គ្រោងចំណាយថវិកាសរុបចំនួន ២ លានដុល្លារសហរដ្ឋអាម៉េរិក។

នៅពេលដែលថវិកាអាចទទួលបានច្បាស់លាស់ និងមានចំនួនគ្រប់គ្រាន់សមរម្យ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អាចនឹងមានលទ្ធភាពកាន់តែប្រសើរជាងនេះសម្រាប់ចាត់ចែងការទទួលខុសត្រូវ និងជំរុញការអនុវត្តសកម្មភាពអភិរក្សទាំងនេះឱ្យទទួលបានជោគជ័យ។

៥. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ការរៀបចំផែនការសកម្មភាពសម្រាប់អភិរក្សដំរីអាស៊ី ដែលមានវិសាលភាពរយៈពេល ១០ ឆ្នាំនេះ(២០២០-២០២៩) ក៏អាចស្របជាមួយនឹងផែនការយុទ្ធសាស្ត្រផ្សេងៗទៀតក្នុងការគ្រប់គ្រងធនធានធម្មជាតិដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាន។ ក្នុងរយៈពេលនៃការអនុវត្តផែនការសកម្មភាពនេះ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលជាអគ្គនាយកដ្ឋានជំនាញរបស់ក្រសួងបរិស្ថានបានសហការជាមួយដៃគូអភិរក្សជាតិ និងអន្តរជាតិនានា នឹងធ្វើការតាមដានបម្រែបម្រួលចំនួនដំរីព្រៃនៅតាមតំបន់នីមួយៗរៀងរាល់៥ឆ្នាំម្តងតាមរយៈវិធីសាស្ត្រ MIKE (Hedges & Lawson 2006)។ ក្រៅពីនេះ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនឹងតាមដានត្រួតពិនិត្យមើលពីបម្រែបម្រួលទីជម្រក និងច្រករបៀងតាមរយៈការបកស្រាយផែនទីគម្របព្រៃពីផ្កាយរណប និងធ្វើការតាមដានស្ថានភាពជម្លោះរវាងមនុស្ស និងដំរីព្រៃ ស្ថានភាពបរបាញ់ និងការប្រើប្រាស់ផលិតផលធ្វើពីសារពាង្គកាយដំរីតាមរយៈរបាយការណ៍ពីកម្មវិធីតាមដាន និងត្រួតពិនិត្យនៅតាមតំបន់អនុវត្តយុទ្ធសាស្ត្រនីមួយៗ។ លទ្ធផលនៃការតាមដានត្រួតពិនិត្យនឹងផ្តល់ទិន្នន័យជាមូលដ្ឋានសម្រាប់វាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តការងារដើម្បីពង្រឹង និងកែតម្រូវសកម្មភាពយុទ្ធសាស្ត្រដែលមិនទាន់សមស្របឱ្យបានល្អប្រសើរឡើង និងទទួលបានជោគជ័យ។

៦. សេចក្តីសន្និដ្ឋាន

ផែនការសកម្មភាពអភិរក្សដំរីអាស៊ីរយៈពេល១០ឆ្នាំនេះ គឺជាលទ្ធផលនៃការប្រមូលព័ត៌មាន និងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធនានាអស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ។ ផែនការសកម្មភាពនេះជាគំនិតផ្តួចផ្តើមលើកដំបូង និងជាផែនទីបង្ហាញផ្លូវទូទាំងប្រទេសមួយ ដែលមិនគ្រាន់តែសម្រាប់បង្ហាញផ្លូវក្នុងបុព្វហេតុអភិរក្ស

ដំរីព្រៃប៉ុណ្ណោះទេ តែក៏សម្រាប់អភិរក្សតំបន់ទេសភាពទាំងមូលនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានដំរីព្រៃជាសត្វបង្គោល(keystone species)។ ផែនការសកម្មភាពនេះក៏អាចយកទៅប្រើប្រាស់ជាឯកសារមូលដ្ឋានមួយសម្រាប់រៀបចំសំណើស្វែងរកថវិកាដើម្បីគាំទ្រសកម្មភាពអភិរក្សនៅក្នុងតំបន់ការពារធម្មជាតិដែរ។ ដំរីអាស៊ីកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់អាចឈានទៅដល់ការផុតពូជនៅទូទាំងដែនជម្រកក្នុងពិភពលោក។ នៅក្នុងប្រទេសកម្ពុជា ដំរីអាស៊ីបានថយចុះក្នុងរយៈពេល ៦០ឆ្នាំចុងក្រោយនេះ ដែលតម្រូវឱ្យមានវិធានការដើម្បីអភិរក្សប្រភេទដ៏សំខាន់នេះសម្រាប់ជាប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់។ ផែនការសកម្មភាពនេះគឺជាឧបករណ៍ដ៏ពិសេសមួយសម្រាប់ទប់ស្កាត់ការផុតពូជដំរីអាស៊ីនៅកម្ពុជា។ បញ្ហាដ៏ធំបំផុតដែលដំរីអាស៊ីកំពុងប្រឈមមុខជាសកលនោះគឺតម្រូវការទីជម្រកជាប់ៗគ្នាដ៏ធំទូលាយ ដែលយ៉ាងហោចណាស់ក៏ត្រូវមានទំហំ ៤ ៤០០គីឡូម៉ែត្រការ៉េដែរ។ តំបន់មានផ្ទៃដីធំបែបនេះនៅក្នុងប្រទេសកម្ពុជានៅមាននៅឡើយ ប៉ុន្តែគ្រាន់តែវាជាច់ៗពីគ្នា ដែលតម្រូវឱ្យមានការស្តារធនាសុវត្ថិភាព និងអភិរក្សសម្រាប់ដំរីអាស៊ីរស់នៅឱ្យបានយូរអង្វែង។ ថនិកសត្វធំៗដូចជាដំរីអាស៊ីនេះមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យមុខងារប្រព័ន្ធអេកូឡូស៊ីអាចដំណើរការបានដោយប្រក្រតី។ ការបាត់បង់ដំរីព្រៃមានន័យថាប្រព័ន្ធអេកូឡូស៊ីព្រៃឈើមានការប្រែប្រួល ដែលអាចធ្វើឱ្យមានការប្រែប្រួលសេវាកម្មបរិស្ថានដែលមនុស្សពឹងអាស្រ័យ ដូចជាការប្រែប្រួលនិយ័តកម្មទឹកភ្លៀងយ៉ាងខ្លាំងជាដើម។ ផែនការសកម្មភាពនេះបង្ហាញពីតម្រូវការនៃការខិតខំប្រឹងប្រែងអភិរក្សដ៏ខ្លាំងថែមទៀត និងការសហការជាមួយអ្នកពាក់ព័ន្ធឱ្យបានទូលំទូលាយដើម្បីសម្រេចឱ្យបានភាពជោគជ័យប្រកបដោយចីរភាពពិតៗ។ ការខិតខំប្រឹងប្រែងនេះអាចអនុវត្តទៅបានដោយផ្អែកទៅលើការចង្អុលបង្ហាញពីថ្នាក់ដឹកនាំដ៏ឈ្លាសវៃ ដែលស្រលាញ់ធម្មជាតិ និងយោងទៅតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស

ប្រកបដោយចីរភាព។ យើងសង្ឃឹមថា ផែនការសកម្មភាពនេះនឹងជួយអភិរក្សដំរីអាស៊ី ក្នុងបុព្វហេតុអភិរក្សកេរមរតកធម្មជាតិសម្រាប់អនាគតបៃតងនៃប្រទេស។

ឯកសារយោង

Choudhury A., Lahiri Choudhury D.K., Desai A., Duckworth J.W., Easa P.S., Johnsingh A.J.T., Fernando P., Hedges S., Gunawardena M., Kurt, F., Karanth U., Lister A., Menon V., Riddle H., Rübel A. and Wikramanayake E. (IUCN SSC Asian Elephant Specialist Group) (2008). *Elephas maximus*. The IUCN Red List of Threatened Species. Version 2015.2. <www.iucnredlist.org>.

Fernando P., and Pastorini J. (2011) Range-wide status of Asian elephants. *Gajah* 35:15-20

Gray T., Vidya T., Bharti S., and Sovanna P. (2014) Population size estimation of an Asian elephant population in eastern Cambodia through non-invasive mark-recapture sampling. *Conservation Genetics* 15:803-810

Hayes, B., Khou E H., Neang T., Furey, N. M., Chhin S., Holden, J., Hun S., Phen S., Pengly La. and Simpson, V. (2015) *Biodiversity Assessment of Prey Lang*. Conservation International. Phnom Penh, Cambodia.

Hedges S., Fisher K., and Rose R. (2008) *Range-wide mapping workshop for Asian elephants (*Elephas maximus*), Cambodia*, October 2008. A report to the U.S. Fish & Wildlife Service on Assistance Award No: 98210-6-G232.

Hedges S. and Lawson D. (2006) *Monitoring the illegal killing of elephants*. Dung survey standards for the MIKE program. CITES MIKE Program, Nairobi, Kenya.

Hing, S. (2012) *A survey of endoparasites in endangered Bornean elephants* Elephas maximus borneensis *in continuous and fragmented habitat*. Thesis, Master of Science. Imperial College London.

Maltby M. and Bourchier G. (2011) Current status of Asian elephant in Cambodia. *Gajah* 35: 36-42.

Pollard E, L. Eggert, C. Cheur and S. Hedges. (2008). *The Status And Conservation Of Asian Elephants In The Seima Biodiversity Conservation Area, Cambodia*. FA/WCS.

Sukumar, R. (1992). *The Asian Elephant: Ecology and Management*, 2nd edn. Cambridge University Press, Cambridge, UK

រៀបចំដោយ៖

អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន

ឧបត្ថម្ភដោយ៖ អង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ (FFI)

LOS ANGELES ZOO

INTERNATIONAL ELEPHANT FOUNDATION.ORG

FAUNA & FLORA INTERNATIONAL

U.S. FISH & WILDLIFE SERVICE

ELEPHANT FAMILY
Protecting Asian elephants and their habitat

Australia Zoo
Home of The Crocodile Hunter